# ២. ក្របខ័ណ្ឌច្បាប់ជាតិ

## ២-១ ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ

**១២.** ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ត្រូវបានអនុម័តដោយរដ្ឋសភាជាតិ នៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៦ និងប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦។ ច្បាប់ នេះមានគោលដៅ :

- ❖ ការពារលើកកំពស់គុណភាពបរិស្ថាន និងសុខភាពពលរដ្ឋ ដោយធ្វើការទប់ស្កាត់ការកាត់បន្ថយ និងការត្រួតពិនិត្យការបំពុលបរិស្ថាន
- ❖ វាយតំលៃហេតុប៉ះពាល់បរិស្ថាន មុននឹងចេញសេចក្តីសំរេចរបស់រាជរដ្ឋាភិបាល ចំពោះរាល់គំរោងដែលបានស្នើឡើង
- ❖ ធានាឱ្យមានការអភិរក្ស ការអភិវឌ្ឍន៏ ការគ្រប់គ្រង និងការប្រើប្រាស់ដោយសមហេតុផល និងប្រកបដោយនិរន្តរភាព និងភាពស្ថិតស្ថេរនូវធនធានធម្មជាតិនៃព្រះរាជាណាចក្រកម្ពុជា
- ❖ លើកទឹកចិត្ត និងផ្តល់លទ្ធភាពឱ្យសាធារណៈជនចូលរួមក្នុងការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- ❖ បង្ក្រាបអំពើទាំងឡាយណាដែលធ្វើឱ្យប៉ះពាល់ដល់បរិស្ថាន។

**១៣.** ទាក់ទងនឹងការគ្រប់គ្រងនូវធនធានធម្មជាតិ ច្បាប់នេះបានតំរូវឱ្យបណ្តាក្រុមហ៊ុនទាំងអស់ត្រូវរៀបចំរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង (IEIA) ឬរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញ (EIA) ។ ផ្អែកលើច្បាប់នេះបានចែងនៅក្នុងមាត្រាទី៦ និង ទី៧ នៃជំពូកទី ៣ ដូចខាងក្រោម :

**<u>មាត្រា៦</u> :**

- ❖ ការវាយតំលៃហេតុប៉ះពាល់បរិស្ថានត្រូវអនុវត្តលើគំរោង និងសកម្មភាពរបស់ឯកជន ឬសាធារណៈហើយត្រូវបានពិនិត្យ និងវាយតំលៃដោយក្រសួងបរិស្ថានមុនដាក់ជូនរាជរដ្ឋាភិបាលសំរេច។
- ❖ ការវាយតំលៃនេះត្រូវអនុវត្តផងដែរ ចំពោះសកម្មភាពដែលមានស្រាប់ និងកំពុងតែមានដំណើរការហើយដែលពុំទាន់បានវាយតំលៃហេតុប៉ះពាល់បរិស្ថាននៅឡើយ ។
- ❖ បែបបទនៃកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងបរិស្ថាន។
- ❖ ប្រភេទនិងទំហំគំរោង និងសកម្មភាពដែលបានស្នើឡើង ព្រមទាំងសកម្មភាពដែលមានស្រាប់ និងកំពុងដំណើរការទាំងឯកជន និងសាធារណៈដែលត្រូវមានការវាយតំលៃហេតុប៉ះពាល់បរិស្ថាននេះត្រូវកំណត់ ដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងបរិស្ថាន។

Draft

មាត្រា៧ :

❖ ចំពោះរាល់ពាក្យសុំធ្វើគំរោងវិនិយោគ និងរាល់គំរោងដែលរដ្ឋស្នើឡើង ត្រូវមានការវាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង (IEIA) ឬការវាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញ (EIA) ដូចមានចែងក្នុងមាត្រា៦ នៃច្បាប់នេះ។ ក្រសួងបរិស្ថានត្រូវពិនិត្យ និងផ្តល់យោបល់លើ IEIA ឬ EIA ទៅអង្គការមានសមត្ថកិច្ច ក្នុងរយៈពេលដូចបានកំណត់ក្នុងច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា។

## ២-២ ច្បាប់ស្តីពីព្រៃឈើ

១៤. ច្បាប់ស្តីពីព្រៃឈើត្រូវបានអនុម័តដោយរដ្ឋសភាជាតិ នៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០២ ហើយដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី១៥ ខែសីហា ឆ្នាំ២០០២ និងប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២។ មាត្រាដែលពាក់ព័ន្ធនឹងការ វាយតំលៃហេតុប៉ះពាល់បរិស្ថាននៃគំរោងវិនិយោគនេះមានដូចខាងក្រោម :

មាត្រា១ :

❖ ច្បាប់នេះកំណត់អំពីក្របខ័ណ្ឌនៃការគ្រប់គ្រង ការប្រមូលផល ការប្រើប្រាស់ ការធ្វើអាជីវកម្ម ការអភិវឌ្ឍន៍ និងការអភិរក្សព្រៃឈើនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ គោលបំណងនៃច្បាប់នេះគឺធានានូវការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព ដើម្បីផលប្រយោជន៍សង្គម-សេដ្ឋកិច្ច និងបរិស្ថាន រួមទាំងការអភិរក្សជីវៈចំរុះ និងមរតកវប្បធម៌។

មាត្រា៣ :

❖ ការគ្រប់គ្រងព្រៃឈើត្រូវស្ថិតនៅក្រោមដែនសមត្ថកិច្ចទូទៅ នៃក្រសួងកសិកម្ម-រុក្ខាប្រមាញ់ និងនេសាទ។ ការគ្រប់គ្រងព្រៃលិចទឹកស្ថិតនៅក្រោមច្បាប់មួយដោយឡែក។ រដ្ឋផ្តល់សិទ្ធិគ្រប់គ្រងតំបន់ការពារធម្មជាតិដល់ក្រសួងបរិស្ថាន ក្រោមបទបញ្ញត្តិទាំងឡាយនៃច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធម្មជាតិ ចុះនៅថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ព្រះរាជក្រឹត្យស្តីពីការបង្កើតនិងកំណត់តំបន់ការពារធម្មជាតិ ចុះនៅថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ និងលិខិតបទដ្ឋានច្បាប់ផ្សេងទៀត។

❖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានសិទ្ធិសហការធ្វើសកម្មភាពពង្រឹងការអនុវត្តន៍ច្បាប់ចំពោះរាល់បទល្មើសព្រៃឈើ ដែលកើតមាននៅក្នុងតំបន់ការពារធម្មជាតិ ក្រោមការសំរបសំរួលជាមួយក្រសួងបរិស្ថាន ស្របតាមបទបញ្ញត្តិ ដូចមានចែងនៅក្នុងជំពូកទី១៤ នៃច្បាប់នេះ។

❖ សកម្មភាពនេះមិនធ្វើឱ្យប៉ះពាល់ដែនសមត្ថកិច្ចគ្រប់គ្រងរបស់ក្រសួងបរិស្ថាន ដូចចែងក្នុងច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិឡើយ។

Draft

**<u>មាត្រា៤</u> :**

- ❖ ក្នុងការអនុវត្តច្បាប់នេះ រាល់ការសំរេចរបស់រដ្ឋាភិបាល ដែលមានសក្តានុភាពចំពោះហេតុប៉ះពាល់ធ្ងន់ធ្ងរទៅលើប្រជាពលរដ្ឋទូទៅលើសហគមន៍មូលដ្ឋាន និងលើធនធានព្រៃឈើនៃព្រះរាជាណាចក្រកម្ពុជា ត្រូវមានការចូលរួមជាសាធារណៈ ។
- ❖ សកម្មភាពចំបងៗ ដែលពាក់ពន្ធ័ទៅនឹងប្រព័ន្ធមជ្ឈដ្ឋានព្រៃឈើ ដែលអាចបណ្តាលឱ្យមានការប៉ះពាល់អាក្រក់ដល់សង្គមនិងបរិស្ថាន ចាំបាច់ត្រូវមានការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងហេតុប៉ះពាល់សង្គម ដោយផ្អែកលើក្រុមបច្ចេកទេសគ្រប់គ្រងព្រៃឈើកម្ពុជា និងស្របតាមច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ។
- ❖ ឯកសារវាយតំលៃហេតុប៉ះពាល់បរិស្ថាននិងសង្គម ត្រូវផ្តល់ជូនសំរាប់ការចូលរួមផ្តល់មតិជាសាធារណៈ រាល់ការសំរេចចុងក្រោយលើសកម្មភាពចំបងៗពាក់ពន្ធ័ទៅនឹងប្រពន្ធ័មជ្ឈដ្ឋានព្រៃឈើ រាជរដ្ឋាភិបាល ត្រូវពិចារណាលើអនុសាសន៍ចុងក្រោយនៃការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ។ ការសំរេចចុងក្រោយ ណាមួយក្រោមមាត្រានេះរាជរដ្ឋាភិបាលអាចជូនដំណឹងជាសាធារណៈ ។

**<u>មាត្រា៣៧</u> :**

- ❖ សហគមន៍មូលដ្ឋានដែលប្រកបរបរចំការពនេចរមានលក្ខណៈប្រពៃណី អាចអនុវត្តលើដីកម្មសិទ្ធិសហគមន៍ជនជាតិភាគតិចដែលបានចុះបញ្ជីការួចហើយជាមួយរដ្ឋ។ ផ្នែករដ្ឋបាលព្រៃឈើនៃមូលដ្ឋាននេះ ត្រូវផ្តល់ការអនុញ្ញាតការគ្រប់គ្រង និងការត្រួតពិនិត្យនៃសកម្មភាពនេះ ដែលជាផ្នែកមួយនៃផែនការគ្រប់គ្រងព្រៃសហគមន៍នោះ។ ការអនុវត្តន៏ចំការពនេចរ ត្រូវហាមឃាត់ចំពោះព្រៃធម្មជាតិទាំងឡាយណាដែលមិនទាន់មានការប៉ះពាល់ក្នុងដែនព្រៃបំរុងទុកអចិន្ត្រៃយ៍ ។ ដីព្រៃឈើដែលរៀបចំសំរាប់ចំការពនេចរ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**<u>មាត្រា៣៩</u> :**

- ❖ គ្មានរូបវន្ត័បុគ្គលណាមានសិទ្ធិផ្តល់ការអនុញ្ញាតិ ទោះបីដោយផ្ទាល់ក្តី ឬដោយប្រយោលក្តីឱ្យកាប់ដើមឈើ ឬធ្វើសកម្មភាពគ្រប់យ៉ាងដើម្បីប្រមូលផល អនុផលព្រៃឈើ ឬកាន់កាប់ដីក្នុងដែនព្រៃបំរុងទុកអចិន្ត្រៃយ៍ផ្ទុយនឹងបទបញ្ញាតិនៃច្បាប់នេះឡើយ ។

**<u>មាត្រា៩៤</u> :**

- ❖ បុគ្គលណាដែលបានប្រព្រឹត្តបទល្មើសព្រៃឈើ ធ្វើឱ្យប៉ះពាល់ខូចខាតដល់មជ្ឈដ្ឋានព្រៃឈើត្រូវចេញថ្លៃស្តារ ឬជូសជុលការខូចខាតមានលក្ខខ័ណ្ឌដូចដើមឡើងវិញ ។

Draft

## ២-៣ ច្បាប់ភូមិបាល

**មាត្រា៣ :**

❖ ជនគ្រប់រូបត្រូវគោរពទ្រព្យសម្បត្តិរបស់រដ្ឋ និងកម្មសិទ្ធិឯកជនស្របច្បាប់លើអចលនវត្ថុ។ ការគ្រប់គ្រងផ្នែករដ្ឋបាលសុរិយោដីលើអចលនវត្ថុដែលជាទ្រព្យសម្បត្តិរបស់រដ្ឋ និងការចេញប័ណ្ណកម្មសិទ្ធិលើអចលនវត្ថុទូទាំងព្រះរាជាណាចក្រកម្ពុជា ជាសមត្ថកិច្ចរបស់ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់។ បទបញ្ញា និងនិតិវិធីនៃការគ្រប់គ្រងអចលនវត្ថុដែលជាទ្រព្យសម្បត្តិរដ្ឋនឹងត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៤៣ :**

❖ ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មិនអាចជាកម្មវត្ថុនៃលទ្ធកម្មកម្មសិទ្ធិបានឡើយ ទោះជាក្នុងករណីណាក៏ដោយ។ ស្ថានភាពនៃអ្នកកាន់កាប់ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនៅតែមិនទៀងទាត់ និងខុសច្បាប់ដដែល ប្រសិនជាស្ថានភាពនោះមិនកើតចេញពីការអនុញ្ញាតិតាមបែបផែនដែលបានកំណត់ដោយច្បាប់ទេនោះ។ បុគ្គលកាន់កាប់ខុសច្បាប់ ត្រូវបង្ខំចិត្តឱ្យចាកចេញជាបន្ទាន់ ហើយត្រូវទទួលទណ្ឌកម្មដែលបានកំណត់ក្នុងមាត្រា ២៥៩ នៃច្បាប់នេះ។ បុគ្គលកាន់កាប់ខុសច្បាប់ គ្មានសិទ្ធិទាមទារសំណងសំរាប់ចំណាយលើការងារ និងការកែលំអដែលខ្លួនបានធ្វើនៅលើអចលនវត្ថុនោះឡើយ។

**មាត្រា៥៨ :**

❖ សម្បទានដី អាចធ្វើឡើងបានតែនៅលើដីដែលជាចំណែកនៃទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ។ សម្បទានដីមិនអាចប៉ះពាល់ផ្លូវគមនាគមន៍ ដីចំណីផ្លូវ និងដីចាំបាច់សំរាប់ថែទាំ ក៏ដូចជាផ្លូវទឹក ត្រពាំង បឹង និងដែនទឹកបំរុងដែលមានប្រយោជន៍ដល់ការរស់នៅរបស់ប្រជាពលរដ្ឋឡើយ។

## ២-៤ ច្បាប់ការងារ

### ២-៤-១ ប្រាក់ឈ្នួល

**មាត្រ១០២ :**

❖ តាមន័យនៃច្បាប់នេះ ពាក្យថាប្រាក់ឈ្នួល ទោះបីការកំណត់ ឬរបៀបគិតយ៉ាងណាក៏ដោយមាន ន័យថា ឈ្នួលការងារ ឬឈ្នួលសេវាដែលអាចគិតជាប្រាក់បាន ឬកិរិតបានដោយការព្រមព្រៀងគ្នា ឬដោយច្បាប់ជាតិ ហើយដែលនិយោជកត្រូវបើកឱ្យកម្មករនិយោជិកតាមកិច្ចសន្យាជួលការងារ ឬសេវា ដោយលាយល័ក្ខណ៏អក្សរ ឬដោយមាត់ទទេ ទោះចំពោះការងារដែលបានធ្វើក្ដី ឬដែលត្រូវធ្វើក្ដី ចំពោះសេវាដែលបានបំពេញ ឬត្រូវបំពេញក្ដី ។

**មាត្រា ១៦១ :**

❖ រៀងរាល់ឆ្នាំ ក្រសួងទទួលបន្ទុកវិស័យការងារ ចេញប្រកាសកំណត់ថ្ងៃបុណ្យដែលត្រូវឈប់មានប្រាក់

ឈ្នួលសំរាប់កម្មករនិយោជិកនៃសហគ្រាសទាំងអស់។ ថ្ងៃបុណ្យឈប់សំរាកមានប្រាក់ឈ្នួលទាំងឡាយនេះ មិនផ្តាច់ចិរវេលាធ្វើការដែលត្រូវគិតដើម្បីឱ្យឈប់សំរាកប្រចាំថ្ងៃ ឆ្នាំនោះដែរ។

**មាត្រា ១៦២ :**

❖ ក្នុងករណីថ្ងៃបុណ្យដែលត្រូវបានឈប់សំរាកត្រូវចំលើថ្ងៃអាទិត្យនោះ កម្មករនិយោជិកនឹងត្រូវបានឈប់សំរាកមួយថ្ងៃ (០១ ថ្ងៃ) បន្តទៀត។ ការឈប់សំរាកថ្ងៃបុណ្យមិនមែនជាហេតុនាំអោយបន្ថយប្រាក់ឈ្នួលប្រចាំខែ ប្រចាំអឌ្ឍមាស ឬប្រចាំសប្តាហ៍ឡើយ។

**មាត្រា ១៦៣ :**

❖ កម្មករនិយោជិកធ្វើការតាមម៉ោងប្រចាំថ្ងៃ ឬតាមបរិមាណផលិតផលត្រូវមានសិទ្ធបានប្រាក់បំណាច់ស្មើនឹងប្រាក់ឈ្នួលដែលបង់ខាតមកពីការឈប់បុណ្យ ដូចមានចែងក្នុងមាត្រា១៦១ ខាងលើ។ ប្រាក់បំណាច់នេះត្រូវនៅក្នុងបន្ទុកនៃនិយោជក។

**មាត្រា ១៦៤ :**

❖ នៅក្នុងគ្រឹះស្ថាន សហគ្រាសណាដែលមិនអាចបញ្ឈប់ការងារបានដោយសារសកម្មភាពរបស់ខ្លួនតំរូវឱ្យកម្មករនិយោជិកទាំងឡាយដែលជាប់ធ្វើការក្នុងថ្ងៃឈប់បុណ្យ ត្រូវមានសិទ្ធទទួលក្រៅអំពីប្រាក់ឈ្នួលនៃការងារដែលខ្លួនបានធ្វើ នូវប្រាក់បំណាច់មួយដែលនៅលើបន្ទុកនិយោជកដែរ ហើយដែលកំរិតក្នុងប្រកាសក្រសួងទទួលបន្ទុកវិស័យការងារ។

**២-៤-២ ការឈប់សំរាកពិសេស**

**មាត្រា១៧១ :**

❖ និយោជកមានសិទ្ធិអនុញ្ញាត្តឱ្យកម្មករនិយោជិកខ្លួន ឈប់សំរាកជាពិសេសក្នុងឱកាសមានព្រឹត្តិការណ៍ដែលប៉ះពាល់ផ្ទាល់ដល់គ្រួសារនៃកម្មករនិយោជិក។

❖ ក្នុងករណីដែលកម្មករនិយោជិក មិនទាន់អនុវត្តការឈប់សំរាកប្រចាំឆ្នាំទាំងអស់របស់ខ្លួនទេ និយោជកអាចធ្វើការកាត់កងការឈប់សំរាកពិសេសខាងលើពីការឈប់សំរាកប្រចាំឆ្នាំរបស់កម្មករនិយោជិកបានទេ។

❖ ក្នុងករណីដែលកម្មករនិយោជិកបានអនុវត្ត ការឈប់សំរាកប្រចាំឆ្នាំរបស់ខ្លួនរួចអស់ហើយ និយោជកមិនអាចធ្វើការកាត់កងការឈប់សំរាកពិសេសខាងលើពីការឈប់ សំរាកប្រចាំឆ្នាំសំរាប់ឆ្នាំខាងមុខរបស់កម្មករ និងនិយោជិកបានទេ។

❖ ម៉ោងធ្វើការដែលខាតបង់ក្នុងឱកាសឈប់សំរាកពិសេសនេះ អាចនឹងបំពេញវិញបានតាមល័ក្ខខ័ណ្ឌដូចមានក្នុងកំរិតប្រកាសក្រសួងទទួលបន្ទុកវិស័យការងារ។

Draft

## ២-៤-៣ អនាម័យ និងសន្តិសុខនៃកម្មករនិយោជិក

**មាត្រា២៣៨ :**

សហគ្រាស និងគ្រឹះស្ថានដែលចង្អុលក្នុងមាត្រា១ នៃច្បាប់នេះត្រូវរៀបចំឱ្យមានការព្យាបាលបឋម សំរាប់កម្មករនិយោជិករបស់ខ្លួន ។

**មាត្រា ២៣៩ :**

❖ ក្រុមពេទ្យការងារត្រូវដឹកនាំពេទ្យម្នាក់ ឬច្រើននាក់ដោយមាននាមជាគ្រូពេទ្យការងារ ដែលមានភារកិច្ចការពារព្យាបាល កុំឱ្យខូចសុខភាពអ្នកធ្វើការដែលបណ្តាលមកពីការងាររបស់គេ ពិសេសឃ្លាំមើលល័ក្ខខ័ណ្ឌអនាម័យការងារ គ្រោះថ្នាក់នៃជម្ងឺឆ្លង និងស្ថានភាពសុខភាពអ្នកជម្ងឺ ។

**មាត្រា ២៤០ :**

❖ ក្រុមពេទ្យការងារ អាចមានជាពិសេសសំរាប់សហគ្រាសនិមួយៗ ឬមានក្រុមពេទ្យការងារមួយសំរាប់សហគ្រាសច្រើន ប្រើប្រាស់រួមគ្នាតាមសារៈសខាន់នៃសហគ្រាស ។

❖ គិលានដ្ឋាននេះ ត្រូវមានគ្រូពេទ្យកាន់កាប់ផ្ទាល់ ដោយមានគិលានុប្បដ្ឋាក ឬគិលានុប្បដ្ឋានយិកាម្នាក់ ឬច្រើននាក់ជួយធ្វើការផងគិតទៅតាមចំនួនកម្មករនិយោជិក ។

❖ ក្នុងម៉ោងធ្វើការ ទាំងថ្ងៃទាំងយប់ ត្រូវមានគិលានុប្បដ្ឋាក ឬគិលានុប្បដ្ឋាយិកាយ៉ាងតិចម្នាក់នៅយាមប្រចាំការជាអចិន្ត្រៃយ៍ ។

**មាត្រា ២៤៣ :**

❖ កាលណាដែលសហគ្រាសដែលចង្អុលក្នុងមាត្រា២២៨ មានសាខា ឬការដ្ឋានមួយ ឬច្រើនដែលមានប្រើកម្មករនិយោជិកយ៉ាងតិចហាសិប(៥០នាក់) ហើយស្ថិតនៅចម្ងាយលើសពីប្រាំ (០៥)គីឡូម៉ែត្រពីការដ្ឋានធំ និយោជកត្រូវតែផ្តល់ចំពោះសាខា ឬការដ្ឋានទាំងនោះឱ្យដូចចំពោះការដ្ឋានធំដែរនូវមធ្យោបាយសង្គ្រោះ និងព្យាបាលកម្មករនិយោជិកខ្លួនឱ្យបានសព្វគ្រប់ដូចជា បុគ្គលិកពេទ្យ សំណង់ សំភារៈ វត្ថុរំរបួស និងថ្នាំព្យាបាល ។

**មាត្រា ២៤៥ :**

❖ ក្រៅពីវិធានការដែលចែងក្នុងមាត្រាខាងលើ និយោជកត្រូវចាត់ចែងដោយចេញសោហ៊ុយខ្លួនឯងនូវ :

១- ក្រុមគីមីបង្ការរោគ នៅក្នុងការដ្ឋានខ្លួន

២- ការចាក់ថ្នាំការពារជម្ងឺឆ្លងទាំងឡាយ ។

❖ ក្នុងពេលមានជម្ងឺឆ្លង ក្រសួងសុខាភិបាលអាចតម្រូវឱ្យមានចាត់វិធានការ ការពារជាពិសេសនៅក្នុងការដ្ឋានទាំងអស់ ។ (ដកស្រង់ពីឯកសារច្បាប់ស្តីពី ការងារ ខែតុលា ឆ្នាំ១៩៩៨) ។

Draft

## ២-៥ ច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា

**១៥.** ច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបានអនុមត័ដោយរដ្ឋសភាជាតិ កាលពីថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៧ នាសម័យប្រជុំពេញអង្គលើកទី៦ នីតិកាលទី៣ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាមលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៧ នាសម័យប្រជុំពេញអង្គលើកទី៣ នីតិកាលទី២ និងប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/០៦០៧/០១៦ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៧។ មាត្រាដែលពាក់ព័ន្ធនឹងការវាយតំលៃហេតុប៉ះពាល់បរិស្ថាននៃគំរោងវិនិយោគនេះមានដូចខាងក្រោម :

<u>មាត្រា១</u> : ច្បាប់នេះមានគោលដៅជំរុញឱ្យមានការគ្រប់គ្រងធនធានទឹកប្រកបដោយប្រសិទ្ធិភាព និងនិរន្តរភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីសំរេចបាននូវការងារអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គម និងសុខមាលភាពរបស់ប្រជាពលរដ្ឋ។ ច្បាប់នេះកំណត់អំពី :

- សិទ្ធិ និងកាតព្វកិច្ចនៃអ្នកប្រើប្រាស់ទឹក
- គោលការណ៍គ្រឹះសំខាន់ៗ សំរាប់ការគ្រប់គ្រងធនធានទឹក
- ការចូលរួមរបស់សហគមន៍អ្នកប្រើបាស់ទឹក ក្នុងការអភិវឌ្ឍន៍ធនធានទឹកប្រកបដោយនិរន្តរភាព។

<u>មាត្រា ៣</u> : ទឹក និងធនធានទឹក ជាសម្បត្តិរបស់រដ្ឋ។

<u>មាត្រា ១១</u> : បុគ្គលគ្រប់រូបមានសិទ្ធិប្រើប្រាស់ធនធានទឹកក្នុងបរិមាណមួយ មិនលើសពីសេចក្តីត្រូវការចាំបាច់ជាមូលដ្ឋានសម្រាប់ការហូបចុក បោកគក់ ងូត និងតម្រូវការផ្សេងៗ រួមមានការចិញ្ចឹមសត្វ ការចិញ្ចឹមត្រីការស្រោចស្រពសួនច្បារ និងដំណាំ ដោយចៀសវាងមិនឱ្យមានការប៉ះពាល់ដល់សិទ្ធិស្របច្បាប់របស់អ្នកដទៃ។ តម្រូវការខាងលើនេះ មិនតម្រូវឱ្យសុំអាជ្ញាបណ្ណ័ទឹកឡើយ។

<u>មាត្រា ១២</u> : ការបង្វែរទឹក ការយកទឹក ការប្រើប្រាស់ធនធានទឹក ក្នុងគោលបំណងកសិកម្ម ឬ ឧស្សាហកម្ម លើសពីកំរិតដែលមានចែងក្នុងមាត្រា ១១ និងសំណង់ការងារទឹកដែលពាក់ព័ន្ធ តម្រូវឱ្យមានការសុំអាជ្ញាបណ្ណ័ទឹក ឬលិខិតអនុញ្ញាត។ បែបបទនៃការសុំនេះ និងមានចែងនៅក្នុងអនុក្រឹត្យ។ ការយកខ្សាច់ដី ឬគ្រួសប្រេងកាត និងឧស្ម័នពីបាត ច្រាំង ឆ្នេរ សមុទ្រ ឆ្នេរទន្លេ ស្ទឹង ព្រែក អូរ បឹងបួ តម្រូវឱ្យមានការសុំអាជ្ញាប័ណ្ណទឹក។ បែបបទបច្ចេកទេសជលសាស្ត្រដែលពាក់ព័ន្ធនឹងការងារនេះ នឹងមានចែងលំអិតនៅក្នុងអនុក្រឹត្យ។ ការលុបទន្លេ ស្ទឹង ព្រែក អូរ ប្រឡាយ បឹងបួ អាងទឹក និងអាងធម្មជាតិ តម្រូវឱ្យមានការសុំអាជ្ញាប័ណ្ណទឹក ឬលិខិតអនុញ្ញាតិ។ បែបបទនៃការសុំនេះ នឹងមានចែងនៅក្នុងអនុក្រឹត្យ។ ការសាងសង់ស្ពានតូច ធំ កាត់ទន្លេ ស្ទឹង កំពង់ផែ ឬសំណង់អាគារតូច ធំលើច្រាំង និងឆ្នេរតម្រូវឱ្យមានការឯកភាពផ្នែកបច្ចេកទេសជាមុនពីក្រសួង

ធនធានទឹក និងឧតុនិយម។ ការបង្វែរទឹកពីប្រភពដើមចេញពីទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវមានការអនុញ្ញាតិ និងយល់ព្រមពីរាជរដ្ឋាភិបាលកម្ពុជា ដោយមានការអនុម័តយល់ព្រមពីស្ថាប័ននីតិបញ្ញត្តិ។

**មាត្រា ១៤** : មុនពេលផ្តល់អាជ្ញាប័ណ្ណទឹកដល់បុគ្គលណាមួយ ក្រសួងធនធានទឹក និងឧតុនិយម ត្រូវពិគ្រោះយោបល់ជាមួយស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋានលើការប្រើប្រាស់ទឹក និងការសាងសង់ សំណង់ការងារទឹកដែលបុគ្គលនោះស្នើឡើង។

**មាត្រា ២២** : រាល់ការបញ្ចេញចោល ការទុកចោល ឬការរក្សាទុកនូវសារធាតុពុលដែលអាចធ្វើឱ្យប៉ះពាល់ដល់គុណភាពទឹក និងអាចបង្កគ្រោះថ្នាក់ដល់មនុស្ស សត្វ និងរុក្ខជាតិ ត្រូវតែសុំអាជ្ញាប័ណ្ណទឹក ឬការអនុញ្ញាតិ។ ប្រភេទសារធាតុពុលដែលមានចែងខាងលើ និងស្តង់ដារបច្ចេកទេសនៃការបញ្ចេញទឹក សំណល់នឹងមានកំណត់ដោយអនុក្រឹត្យ។ រាល់កិច្ចដំណើរការក្នុងមាត្រានេះ ក្រសួងធនធានទឹក និងឧតុនិយម ត្រូវពិគ្រោះយោបល់ជាមួយក្រសួងពាក់ព័ន្ធនានា។

**មាត្រា ២៣** : ក្រសួងធនធានទឹក និងឧតុនិយម អាចប្រកាសទុកជាតំបន់អាសន្ន ឬជាតំបន់ហាមឃាត់ការប្រើប្រាស់ទឹកក្នុងករណីដែល :

- ទឹកលើដី ឬទឹកក្រោមដីត្រូវបានប៉ះពាល់ផ្នែកបរិមាណ គុណភាព ឬតុល្យភាពអេកូឡូស៊ី។
- ទឹកលើទីជំរាលដែលកំពុងរងការគំរាមគំហែងដោយសកម្មភាពមនុស្ស ឬធម្មជាតិ។
- ទឹកដែលបណ្តាលឱ្យប៉ះពាល់ដល់សុខភាពប្រជាពលរដ្ឋ។

ដែនភូមិសាស្ត្រនៃតំបន់អាសន្ន ឬតំបន់ហាមឃាត់នោះ ត្រូវកំណត់តាមករណីនិមួយៗដោយប្រកាសរបស់ក្រសួងធនធានទឹក និងឧតុនិយម។

## ២-៦ ច្បាប់ស្តីពីជីវសុវត្ថិភាព

**១៦.** ច្បាប់ស្តីពីជីវសុវត្ថិភាព ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០០៧ នាសម័យប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី៣ ហើយដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងដោយគ្មានការកែប្រែអ្វីឡើយកាលពីថ្ងៃទី១៨ ខែមករា ឆ្នាំ២០០៨ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី៤ នីតិកាលទី២ និងប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២០៨/០០៦ ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០០៨ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ:

**មាត្រា ១**: ច្បាប់នេះមានគោលបំណងៈ អនុវត្តគោលការណ៍ប្រុងប្រយ័ត្នស្តីពីជីវសុវត្ថិភាព ទប់ស្កាត់ ផលប៉ះពាល់អវិជ្ជមានទៅលើការអភិរក្សជីវៈចម្រុះ និងធនធានធម្មជាតិនៃព្រះរាជាណាចក្រកម្ពុជា ដែលបណ្តាលមកពីការផលិត ការដឹកជញ្ជូនឆ្លងដែន ការអភិវឌ្ឍ ការលើកដាក់ ការផ្ទេរ ការប្រើប្រាស់ ការស្តុកទុក និងការបញ្ចេញសារពាង្គកាយកែច្នៃរស់ ដែលបង្កើតឡើងដោយជីវបច្ចេកវិទ្យាទំនើប។ ធានាប្រសិទ្ធិភាពនៃការ



Draft

អភិរក្ស និងការប្រើប្រាស់ជីវៈចម្រុះដោយនិរន្តរភាព ព្រមទាំងយកចិត្តទុកដាក់ចំពោះហានិភ័យដល់សុខភាពមនុស្ស ធ្វើអោយមានតម្លាភាពក្នុងនីតិវិធីពិនិត្យ និងក្នុងការធ្វើសេចក្តីសំរេចចំពោះសារពាង្គកាយ កែច្នៃរស់ និងសកម្មភាពទាំងឡាយដែលទាក់ទងនឹងសារពាង្គកាយ កែច្នៃរស់។ លើកកំពស់ ការយល់ដឹងអំពីជីវបច្ចេកវិទ្យាទំនើបសំដៅទប់ស្កាត់ហានិភ័យពីការប្រើប្រាស់ និងការបញ្ចេញសារពាង្គកាយកែច្នៃរស់ទៅក្នុងបរិស្ថាន និងសុខភាពមនុស្ស។

<u>មាត្រា៣:</u> ច្បាប់នេះអនុវត្តចំពោះការនាំចូល និងនាំចេញ ការប្រើប្រាស់ក្នុងព្រំដែនកំណត់ ការបញ្ចូលសារពាង្គកាយកែច្នៃរស់ទៅក្នុងបរិស្ថានដោយចេតនា និងការប្រើប្រាស់ផ្ទាល់ដើម្បីជាម្ហូបអាហារ ឬចំណីសត្វ ឬដើម្បីកែច្នៃរស់ ដែលអាចប៉ះពាល់ដល់ការអភិរក្ស និងការប្រើប្រាស់ជីវៈចម្រុះដោយនិរន្តរភាព ព្រមទាំងបញ្ហាសុខភាពមនុស្សផងដែរ។ ច្បាប់នេះនឹងមិនអនុវត្តចំពោះសារពាង្គកាយកែច្នៃរស់ សំរាប់ប្រើជាឱសថដែលមានចែងក្នុងកិច្ចព្រមព្រៀងអន្តរជាតិដែលពាក់ព័ន្ធ។ សារពាង្គកាយកែច្នៃរស់ដែលគ្រាន់តែដឹកជញ្ជូនឆ្លងកាត់ តែពុំមានទិសដៅយកមកប្រើនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ប្រភេទសារពាង្គកាយកែច្នៃរស់មួយចំនួនទៀត ដែលត្រូវបានលើកលែងដោយស្ថាប័នមានសមត្ថកិច្ច។ ផលិតផលសារពាង្គកាយ កែច្នៃរស់មិនមានជីវិត ឬ ក៏សមាសភាពនៃសាពាង្គកាយអជីវិតកែច្នៃសេនេទិច។

<u>មាត្រា ៤:</u> រូបវន្តបុគ្គល ឬ នីតិបុគ្គល ដែលបានផ្តល់ដំណឹងថាមានបំណងធ្វើសកម្មភាព ឬ ប្រតិបត្តិការទាក់ទងនឹងសារពាង្គកាយកែច្នៃរស់ ដូចជា ការប្រើប្រាស់ក្នុងព្រំដែនកំណត់ការបញ្ចូលទៅក្នុងបរិស្ថានដោយចេតនា និង ឬ ដើម្បីប្រើប្រាស់ដោយផ្ទាល់ធ្វើជាម្ហូបអាហារ ជាចំណីសត្វ ឬ ដើម្បីកែច្នៃនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវមានការឯកភាពជាមុនពីក្រសួងបរិស្ថាន មុននឹងសុំការអនុញ្ញាតពីស្ថាប័នមានសមត្ថកិច្ចដែលពាក់ព័ន្ធ។ សកម្មភាព ឬប្រតិបត្តិការណាមួយដែលពាក់ព័ន្ធនឹងសារពាង្គកាយកែច្នៃរស់ ក្រោមបទប្បញ្ញត្តិនៃច្បាប់នេះ ត្រូវអនុវត្តស្របតាមស្តង់ដា និងវិធានការស្តីពីការគ្រប់គ្រង និងត្រួតពិនិត្យអំពីហានិភ័យដូចដែលបានកំណត់ក្នុងនីតិវិធីស្តីពីការវាយតំលៃហានិភ័យ ដូចបានចែងក្នុងជំពូកទី៥ ហើយនិងមានចែងលម្អិតដោយប្រកាសរបស់ក្រសួងបរិស្ថាន បន្ទាប់ពីមានការពិគ្រោះយោបល់ជាមួយស្ថាប័នមានសមត្ថកិច្ចដែលពាក់ព័ន្ធ។

<u>មាត្រា ៦:</u> ក្រសួងបរិស្ថាន ដោយសហការជាមួយក្រសួងពាក់ព័ន្ធត្រូវត្រួតពិនិត្យរាល់សកម្មភាព និងប្រតិបត្តិការដែលពាក់ព័ន្ធនឹងសារពាង្គកាយកែច្នៃរស់ ដែលបានបញ្ញត្តិនៃច្បាប់នេះ។ ក្រសួងបរិស្ថាន ជាស្ថាប័នបង្គោលជាតិ និងជាស្ថាប័នមានសមត្ថកិច្ចក្នុងការអនុវត្តបទបញ្ញត្តិនៃច្បាប់នេះ។

<u>មាត្រា ៧:</u> ក្នុងការទទួលខុសត្រូវជាស្ថាប័នបង្គោលជាតិ ដូចបានចែងក្នុងមាត្រា៦ ខាងលើនេះ ក្រសួងបរិស្ថានត្រូវធ្វើជាស្ថាប័នទំនាក់ទំនងដំបូងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងលេខាធិការដ្ឋានអនុសញ្ញាជីវៈចម្រុះ។ ក្នុងតួនាទីជាស្ថាប័នមានសមត្ថកិច្ចរបស់ជាតិ ក្រសួងបរិស្ថានត្រូវទទួលខុសត្រូវក្នុងការបំពេញមុខងាររដ្ឋបាលដែលបានតំរូវសំរាប់អនុវត្តច្បាប់នេះ។ មុខងារទាំងនេះរួមមានការជូនដំណឹងទាន់ពេលវេលាទៅប្រទេស

Draft

ដទៃទៀត និងមណ្ឌលចែកចាយព័ត៌មានជីវសុវត្ថិភាព ព្រមទាំងអង្គការអន្តរជាតិ ដែលពាក់ព័ន្ធទាំងឡាយក្នុងករណីមានហេតុការណ៍ណាមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលបណ្តាលមកពីចលនាឆ្លងដែនណាមួយដោយអចេតនានៃសារពាង្គកាយកែច្នៃរស់។ មន្ត្រីរបស់ក្រសួងបរិស្ថានដែលត្រូវបានចាត់តាំង ដោយសហការជាមួយមន្ត្រីជំនាញនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាចធ្វើអធិការកិច្ច អាចប្រមូលយកគំរូតាង ឬវត្ថុតាងដើម្បីសំរួលដល់ការស៊ើបអង្កេតក្នុងទីតាំងដែលបាន ឬកំពុងមានសកម្មភាព ឬប្រតិបត្តិការទាក់ទងនឹងសារពាង្គកាយកែច្នៃរស់។

<u>មាត្រា ១១:</u> ការនាំចូលសារពាង្គកាយកែច្នៃរស់មកក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីបញ្ចូលទៅក្នុងបរិស្ថានដោយចេតនា ត្រូវបានតំរូវអោយមានការវាយតំលៃហានិភ័យ ព្រមទាំងមានការយល់ព្រមពីក្រសួងបរិស្ថានជាមុន មុននឹងស្នើសុំការអនុញ្ញាតនាំចូលពីស្ថាប័នមានសមត្ថកិច្ចដែលពាក់ព័ន្ធ។ ម្ចាស់ស្នើត្រូវដាក់ពាក្យទៅក្រសួងបរិស្ថាន អំពីគោលបំណងនៃការនាំចូលរបស់ខ្លួន។

<u>មាត្រា ១៩ :</u> អ្នកនាំចេញសារពាង្គកាយកែច្នៃរស់ ពីព្រះរាជាណាចក្រកម្ពុជា ត្រូវមានការបញ្ជាក់ជាលាយលក្ខណ៏អក្សរពីក្រសួងបរិស្ថាន ពីភាពត្រឹមត្រូវនៃរាល់ព័ត៌មានដែលខ្លួនបានផ្តល់ទាក់ទងនឹងសារពាង្គកាយកែច្នៃរស់ត្រូវនាំចេញ។ លិខិតបញ្ជាក់នេះត្រូវភ្ជាប់ជាមួយនឹងលិខិតអនុញ្ញាតនាំចេញ និង/ឬឯកសារដទៃទៀតទាក់ទងនឹងការវេចខ្ចប់ ការលើកដាក់នាំចេញ។

<u>មាត្រា ២១ :</u> ម្ចាស់សំណើត្រូវទទួលបន្ទុកក្នុងការវាយតំលៃហានិភ័យ និងទទួលរ៉ាប់រងលើចំណាយទាំងអស់សំរាប់ការវាយតំលៃនេះ។ នៅពេលបានទទួលលទ្ធផលនៃការវាយតំលៃហានិភ័យ និងឯកសារពាក់ព័ន្ធទាំងឡាយដែលបានតំរូវដោយច្បាប់នេះ ក្រសួងបរិស្ថាននឹងផ្តល់ការឯកភាពជាគោលការណ៏ដោយមាន ឬគ្មានលក្ខខណ្ឌ ឬតំរូវអោយផ្តល់ព័ត៌មានបន្ថែម ឬបដិសេធមិនផ្តល់ការឯកភាព។

**២-៧ ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ**

**១៧.** ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៧ នាសម័យប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី៣ ហើយដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយកាលពីថ្ងៃទី១៨ ខែមករា ឆ្នាំ២០០៨ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី៤ នីតិកាលទី២ និងប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ ២០០៨ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

<u>មាត្រា ១ :</u>

ច្បាប់នេះ កំណត់ក្របខ័ណ្ឌនៃការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍន៏តំបន់ការពារធម្មជាតិ។

Draft

គោលបំណងនៃច្បាប់នេះ គឺធានានូវការគ្រប់គ្រង ការអភិរក្សជីវៈចម្រុះ និងការធានាប្រើប្រាស់ធនធានធម្មជាតិក្នុងតំបន់ការពារធម្មជាតិប្រកបដោយនិរន្តរភាព។

**មាត្រា ២ :**

ច្បាប់នេះ មានវិសាលភាពអនុវត្តនៅតំបន់ការពារធម្មជាតិ ដែលកំណត់ដោយបទប្បញ្ញត្តិទាំងឡាយនៃច្បាប់ ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស.រកម.១២៩៦-៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ព្រះរាជក្រឹត្យស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ព្រះរាជក្រឹត្យស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់ជម្រកជីវមណ្ឌលបឹងទន្លេសាប លេខ នស/រកត/០៤០១/០៧០ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០០១ និងលិខិតបទដ្ឋានច្បាប់ផ្សេងទៀត។

**មាត្រា ១១ :**

តំបន់ការពារធម្មជាតិនីមួយៗ បែងចែកជាបួនតំបន់គ្រប់គ្រង :

១. **តំបន់ស្នូល** : ជាតំបន់គ្រប់គ្រងដែលមានតម្លៃខ្ពស់ សម្រាប់ការអភិរក្សប្រភេទសត្វ រុក្ខជាតិ ដែលកម្រ ជិតផុតពូជ ទទួលរងគ្រោះថ្នាក់ គម្រាមកំហែង និងមានប្រព័ន្ធអេកូឡូស៊ីងាយស្រួយ។

ការចេញ ចូលតំបន់នេះត្រូវហាមឃាត់ លើកលែងតែមន្ត្រីរដ្ឋបាលការពារ និងអភិរក្សធម្មជាតិដែលមានភារកិច្ច និងអ្នកសិក្សាស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រធម្មជាតិ ក្នុងគោលបំណងការពារ និងអភិរក្សធនធានធម្មជាតិ ជីវៈចម្រុះ និងបរិស្ថាន ដែលត្រូវមានការអនុញ្ញាតជាមុនពីក្រសួងបរិស្ថាន លើកលែងតែក្នុងវិស័យសន្តិសុខ និងការពារជាតិ។

២. **តំបន់អភិរក្ស** : ជាតំបន់គ្រប់គ្រងស្ថិតនៅជាប់នឹងតំបន់ស្នូល ដែលមានតម្លៃខាងការអភិរក្សធនធានធម្មជាតិ ប្រព័ន្ធអេកូឡូស៊ី តំបន់ទីជម្រាល និងតំបន់ដែលមានលក្ខណៈទេសភាពធម្មជាតិ។

ការចេញ ចូលតំបន់នេះ ត្រូវមានការអនុញ្ញាតជាមុនពីរដ្ឋបាលការពារ និងអភិរក្សធម្មជាតិនៅនឹងកន្លែង លើកលែងតែមានការចាំបាច់ក្នុងវិស័យសន្តិសុខ និង ការពារជាតិ។

ការប្រើប្រាស់អនុផលធនធានធម្មជាតិក្នុងតំបន់នេះ សម្រាប់ជីវភាពសហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច ដែលមិនប៉ះពាល់ខ្លាំងដល់ជីវៈចម្រុះ ត្រូវស្ថិតក្រោមការត្រួតពិនិត្យហ្មត់ចត់របស់រដ្ឋបាលការពារ និងអភិរក្សធម្មជាតិ។

៣. **តំបន់ប្រើប្រាស់ដោយចីរភាព** : ជាតំបន់គ្រប់គ្រង ដែលមានតម្លៃសេដ្ឋកិច្ចខ្ពស់ បំរើដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ការគ្រប់គ្រង ការអភិរក្សតំបន់ការពារធម្មជាតិផ្ទាល់ និងចូលរួមលើកកំពស់ជីវភាពរស់នៅរបស់ប្រជាសហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច។

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា អាចអនុញ្ញាតឱ្យមានការអភិវឌ្ឍ និងការវិនិយោគនៅក្នុងតំបន់នេះ តាមការស្នើសុំរបស់ក្រសួងបរិស្ថាន ក្រោយពីមានការពិគ្រោះយោបល់ពីបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដី និងសហគមន៍មូលដ្ឋាន ដោយអនុលោមតាមច្បាប់ និងនីតិវិធីជាធរមាន។

៤. <u>**តំបន់សហគមន៍**</u> : ជាតំបន់គ្រប់គ្រងបំរើឱ្យការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ចរបស់សហគមន៍ និងជនជាតិដើមភាគតិច ដែលមានសកម្មភាពស្រាប់ រួមមាន លំនៅដ្ឋាន ស្រែ និងចំការ។

ការចេញប័ណ្ណដីធ្លី ឬ ការអនុញ្ញាតឱ្យប្រើប្រាស់ដីធ្លីនៅក្នុងតំបន់នេះ ត្រូវមានការបញ្ជាក់យល់ព្រមជាមុនពីក្រសួងបរិស្ថាន ដោយអនុលោមតាមច្បាប់ភូមិបាល។

តំបន់ការពារធម្មជាតិនេះ មិនគ្របដណ្តប់ទៅលើការកំណត់ និងការចាត់ចែងគ្រប់គ្រងរបស់អាជ្ញាធរអប្សរា និងអាជ្ញាធរដទៃទៀត ដែលរាជរដ្ឋាភិបាលប្រគល់ភារកិច្ចឱ្យ។

<u>**មាត្រា ៤៤ :**</u>

ដើម្បីកាត់បន្ថយជាអតិបរមានូវហេតុប៉ះពាល់បរិស្ថាន និងសង្គម និងសម្រេចឱ្យបាននូវគោលបំណងយុទ្ធសាស្ត្រ នៃការគ្រប់គ្រងតំបន់ការពារធម្មជាតិ រាល់គម្រោងអភិវឌ្ឍ ឬវិនិយោគក្នុងតំបន់ប្រើប្រាស់ដោយចីរភាព និងតំបន់សហគមន៍ ក្រសួងបរិស្ថានត្រូវធ្វើការសិក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ជាមុនដោយសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ។

នីតិវិធីនៃការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គម សម្រាប់គំរោង ឬ សកម្មភាពណាមួយត្រូវអនុលោមតាមបទប្បញ្ញត្តិទាំងឡាយ ដែលពាក់ព័ន្ធនឹងកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គម។

### ២-៨ អនុក្រឹត្យស្តីពីកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន

**១៨.** អនុក្រឹត្យលេខ ៧២ អនក្រ.បក ស្តីពីកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន បានអនុម័តនៅថ្ងៃទី ១១ ខែសីហា ឆ្នាំ១៩៩៩។ អនុក្រឹត្យមានគោលបំណង :

- ❖ កំណត់វាយតំលៃហេតុប៉ះពាល់បរិស្ថានលើគំរោង និងសកម្មភាពរបស់ឯកជន ឬសាធារណៈ ហើយត្រូវបានពិនិត្យ និងវាយតំលៃដោយក្រសួងបរិស្ថានមុនដាក់ជូនរាជរដ្ឋាភិបាលសំរេច។
- ❖ កំណត់ប្រភេទ និងទំហំគំរោង សកម្មភាពដែលស្នើឡើង ព្រមទាំងសកម្មភាពដែលមានស្រាប់ និងកំពុងដំណើរការទាំងឯកជន និងសាធារណៈដែលត្រូវវាយតំលៃហេតុប៉ះពាល់បរិស្ថាន។
- ❖ បំផុសឱ្យមានការចូលរួមពីសាធារណៈជន ក្នុងកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ព្រមទាំងទទួលយកមតិយោបល់មកធ្វើការពិចារណាក្នុងកិច្ចដំណើរអនុវត្តគំរោង។

១៩. យោងតាមឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ក៏មានការចាត់ថ្នាក់ពីប្រភេទគំរោងដែលទាក់ទងទៅនឹងវិស័យកសិកម្ម ដែលទាមទារឱ្យម្ចាស់គំរោងរៀបចំរបាយការណ៍ IEIA ឬ EIA លើគំរោងដីសម្បទានក្នុងការអភិវឌ្ឍន៍ដំណាំកសិ-ឧស្សាហកម្មផងដែរ ។

## ២-៩ អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលទឹក

២០. អនុក្រឹត្យលេខ ២៧ អនក្រ.បក ស្តីពីការត្រួតពិនិត្យការបំពុលទឹកបានអនុម័តនៅថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ១៩៩៩ ។ អនុក្រឹត្យនេះ :

- ❖ មានគោលដៅកំណត់ការត្រួតពិនិត្យការបំពុលទឹក ដើម្បីទប់ស្កាត់ និងកាត់បន្ថយការបំពុលទឹកនៅតាមតំបន់ទឹកសាធារណៈ សំដៅធានាបានការពារសុខភាពមនុស្ស និងការអភិរក្សជីវៈចំរុះ ។
- ❖ មានវិសាលភាពអនុវត្តចំពោះរាល់ប្រភពបំពុល និងរាល់សកម្មភាពទាំងឡាយណា ដែលបង្កឱ្យមានការបំពុលទឹកនៅតាមតំបន់ទឹកសាធារណៈ ។
- ❖ ពាក់ព័ន្ធទៅនឹងអនុក្រឹត្យនេះផងដែរ មានភ្ជាប់ជូននូវឧបសម្ព័ន្ធចំនួន៥ ដើម្បីការពារការបំពុលទឹកសាធារណៈ ក៏ដូចជាការអភិរក្សជីវៈចំរុះ និងសុខភាពមនុស្ស ។
  - **ឧបសម្ព័ន្ធ១** : ប្រភេទសារធាតុប្រកបដោយគ្រោះថ្នាក់
  - **ឧបសម្ព័ន្ធ២** : កំរិតកំណត់ស្តង់ដារនៃការបញ្ចេញសំណល់រាវពីប្រភពបំពុលចូលទៅក្នុងតំបន់ទឹកសាធារណៈ ឬទៅក្នុងប្រព័ន្ធបណ្តាញលូ ។
  - **ឧបសម្ព័ន្ធ៣** : ប្រភេទនៃប្រភពបំពុលដែលតំរូវឱ្យមានការសុំអនុញ្ញាតិ ពីក្រសួងបរិស្ថាន មុននឹងបញ្ចេញចោលនូវសំណល់រាវរបស់ខ្លួន ឬដឹកទៅទីដទៃ ។
  - **ឧបសម្ព័ន្ធ៤** : កំរិតកំណត់ស្តង់ដារគុណភាពទឹកនៅតាមតំបន់ទឹកសាធារណៈសំរាប់អភិរក្សជីវៈចំរុះនៅក្នុងទឹក ។
  - **ឧបសម្ព័ន្ធ៥** : កំរិតកំណត់ស្តង់ដារគុណភាពទឹកនៅតាមតំបន់ទឹកសាធារណៈ សំរាប់ការពារសុខភាពសាធារណៈ ។

## ២-១០ អនុក្រឹត្យស្តីពីការគ្រប់គ្រងសំណល់រឹង

២១. អនុក្រឹត្យលេខ ៣៦ អនក្រ.បក ស្តីពីការគ្រប់គ្រងសំណល់រឹង បានអនុម័តនៅថ្ងៃទី ២៧ ខែ មេសា ឆ្នាំ១៩៩៩ អនុក្រឹត្យនេះ :

- ❖ មានគោលដៅកំណត់ការគ្រប់គ្រងសំណល់រឹង ប្រកបដោយលក្ខណៈបច្ចេកទេសសមស្រប និងប្រកបដោយសុវត្ថិភាពសំដៅធានាបាននូវការការពារសុខភាពសាធារណៈ គុណភាពបរិស្ថាន និងការអភិរក្សជីវៈចំរុះ ។

Draft

- មានវិសាលភាពអនុវត្តចំពោះរាល់សកម្មភាពបោះចោល ទុកដាក់ ស្តុក ប្រមូល ដឹកជញ្ជូន កែច្នៃ និងបញ្ចេញចោលសំរាម និងសំណល់ប្រកបដោយគ្រោះថ្នាក់។
- ពាក់ព័ន្ធទៅនឹងអនុក្រឹត្យនេះ មានភ្ជាប់ជាមួយនូវឧបសម្ព័ន្ធដែលកំណត់ប្រភេទសំណល់ប្រកបដោយគ្រោះថ្នាក់។

## ២-១១ អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំលេង

**២២.** អនុក្រឹត្យលេខ ៤២ អនក្រ.បក ស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំលេងបាន អនុម័តនៅថ្ងៃទី ១០ ខែកក្កដា ឆ្នាំ២០០០។ អនុក្រឹត្យនេះមានគោលដៅ :

- កំណត់ការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំលេង ដើម្បីទប់ស្កាត់ និងកាត់បន្ថយសារធាតុដែលបំពុលខ្យល់ និងសំលេងក្នុងបរិយាកាស សំដៅការពារគុណភាពបរិស្ថាន និងសុខភាពសាធារណៈ។
- មានវិសាលភាពអនុវត្ត និងចាត់វិធានការចំពោះរាល់ប្រភពបំពុលចល័ត និងអចល័តទាំងឡាយណាដែលបង្កឱ្យមានការបំពុលខ្យល់ និងការរំខានដោយសំលេងនៅក្នុងបរិយាកាស។
- ពាក់ព័ន្ធទៅនឹងអនុក្រឹត្យនេះ មានភ្ជាប់ជូននូវឧបសម្ព័ន្ធចំនួន៨ ដើម្បីការពារការបំពុលខ្យល់ និងការរំខានដោយសំលេង ពីប្រភពបំពុលចល័ត និងអចល័តដើម្បីការពារសុខភាពមនុស្ស។
    - **ឧបសម្ព័ន្ធ១** : កំរិតកំណត់ស្តង់ដារគុណភាពខ្យល់
    - **ឧបសម្ព័ន្ធ២** : កំរិតកំណត់ស្តង់ដារជាអតិបរមានៃសារធាតុប្រកបដោយគ្រោះថ្នាក់ដែលអនុញ្ញាតឱ្យមាននៅក្នុងខ្យល់។
    - **ឧបសម្ព័ន្ធ៣** : កំរិតកំណត់ស្តង់ដារជាអតិបរមានៃសារធាតុបំពុល ដែលអនុញ្ញាតបញ្ចេញពីប្រភពអចល័តចូលទៅក្នុងបរិយាកាស។
    - **ឧបសម្ព័ន្ធ៤** : កំរិតកំណត់ស្តង់ដារនៃការបញ្ចេញឧស្ម័នពីប្រភពអចល័ត។
    - **ឧបសម្ព័ន្ធ៥** : កំរិតកំណត់ស្តង់ដារជាអតិបរមាដែលអនុញ្ញាតបញ្ចេញសំលេងនៅលើផ្លូវសាធារណៈពីប្រភពយានយន្ត។
    - **ឧបសម្ព័ន្ធ៦** : កំរិតកំណត់ស្តង់ដារជាសំលេងអតិបរមាដែលអនុញ្ញាតនៅតំបន់សាធារណៈ និងតំបន់លំនៅដ្ឋាន។
    - **ឧបសម្ព័ន្ធ៧** : កំរិតកំណត់ស្តង់ដារសំរាប់ត្រួតពិនិត្យសំលេងក្នុងទីតាំងរោងជាង រោងចក្រឧស្សាហកម្ម។

Draft

- **ឧបសម្ព័ន្ធ៨** : កំរិតកំណត់ស្តង់ដារ ជាតិស្ពាន់ធ័រ សំណ បង់សែន និងអ៊ីដ្រូកាបួប្រហើរ ដែលអនុញ្ញាតឱ្យមាននៅក្នុងប្រេងឥន្ធនៈ និងធ្យូងថ្ម។

## ២-១២ អនុក្រឹត្យស្តីពីដីសម្បទានសេដ្ឋកិច្ច

២៣. អនុក្រឹត្យលេខ ១៤៦ អនក្រ.បក ស្តីពីសម្បទានដីសេដ្ឋកិច្ចបានអនុម័តនៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ ២០០៥ ដោយរាជរដ្ឋាភិបាលកម្ពុជា។ អនុក្រឹត្យនេះគោលដៅកំណត់លក្ខណៈវិនិច្ឆ័យ នីតិវិធីយន្តការ និងការរៀបចំស្ថាប័ន សំរាប់ការផ្តួចផ្តើម និងការផ្តល់ដីសម្បទានសេដ្ឋកិច្ច សំរាប់ការតាមដានត្រួតពិនិត្យការអនុវត្តកិច្ចសន្យា និងសំរាប់ការត្រួតពិនិត្យឡើងវិញលើសម្បទានដីសេដ្ឋកិច្ច ដែលបានចុះកិច្ចសន្យាមុនពេលដែលអនុក្រឹត្យនេះចូលជាធរមាន ស្របតាមការកំណត់នៃច្បាប់ភូមិបាលឆ្នាំ២០០១។ ជាមួយគ្នានេះដែរ អនុក្រឹត្យនេះបានតំរូវឱ្យម្ចាស់គំរោងរៀបចំការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង សំរាប់គំរោងសម្បទានដីសេដ្ឋកិច្ច។ ក្នុងករណីណាការវាយតំលៃដំបូងបានបង្ហាញឱ្យឃើញថា មានហេតុប៉ះពាល់បរិស្ថានអវិជ្ជមានមានកំរិតមធ្យម ឬខ្លាំង ត្រូវរៀបចំការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ។

Draft